ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូននាយកអង្គការ និងអ្នកសំរបសំរួលថវិកាអង្គការកម្ពុជានៃក្តីសង្ឃឹមប្រចាំក្រុងប៉ោយប៉ែត ដែលមានស្នាដៃចូលរួមអនុវត្តកម្មវិធីអេដស៍ តាំងពីឆ្នាំ ២០០៧ និងកសាងផ្លូវបេតុងចូលមណ្ឌលសុខភាពប៉ោយប៉ែត ១ មានទំហំ ៧,៥០ ម៉ែត្រ គុណ ១៨ម៉ែត្រ អណ្តូងទឹក ០១ បំពាក់ដោយម៉ូទ័របូម អាងទឹក កំរាលគ្រែ រទេះរុញមួយ ជួសជុលបង្គន់ ផ្តល់អាហារប្រចាំថ្ងៃ ៣ពេល ដល់អ្នកជំងឺអេដស៍ ផ្តល់ថវិកាធ្វើដំណើរ ដល់អ្នកជំងឺអេដស៍ ចំនួន៣១៤នាក់ ដើម្បីទៅទទួលថ្នាំពន្យារនៅមន្ទីរពេទ្យ សៀមរាប មង្គលបូរី និងប៉ោយប៉ែត ឧបត្ថម្ភដល់យុទ្ធនាការអប់រំ និងទប់ស្កាត់ដល់ការរីករាលដាលនៃជម្ងឺអេដស៍ ដូចមានរាយនាមខាងក្រោម :-

១-លោក **អ៊ិន ជំនោរ (In Chomno)** នាយកអង្គការកម្ពុជា នៃក្តីសង្ឃឹម

២-លោក **អ៊ី វុទ្ធី (Ee Vuthy)** អ្នកសំរបសំរួលថវិកាអង្គការកម្ពុជានៃក្តីសង្ឃឹម

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ១៦៥២-អនក្រ-តត**

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

ៗលៗ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ចំនួន០២គ្រឿង ជូនអ្នកសំរបសំរួលគំរោងនៃអង្គការ M H D និងនាយិកាប្រចាំកម្ពុជា នៃអង្គការ C W S ដែលមានស្នាដៃល្អក្នុងការជួយកសាង និងអភិវឌ្ឍន៍ខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-កញ្ញា **ជូលីណា ហែលមេរិច** អ្នកសំរបសំរួលគំរោង នៃអង្គការ M H D

២-អ្នកស្រី **ចូសេហ្វីន ឆាម៉រ** នាយិកាប្រចាំកម្ពុជា នៃអង្គការ C W S

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ១១ ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ១៦៨៣.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញ ព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

**សម្រេច**

**មាត្រា១._**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនវៀតណាម ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងអគារស្នាក់នៅ ០១ខ្នង ជូនអង្គភាពកងការពារព្រំដែន ៦០១ មានទំហំ ១៥ ម គុណ ៧ ម ដូចមានរាយនាមខាងក្រោម ៖

១-លោក LAM MINH YIANG    ប្រធានគណៈកម្មាធិការប្រជាជន ស្រុកអានភូ ខេត្តអានយ៉ាង
២-លោក PHAM MINH TRI    ប្រធានលេខាបក្ស ស្រុកអានភូ ខេត្តអានយ៉ាង

**មាត្រា២._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៦៨៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ខេព ធន** វរមន្ត្រីថ្នាក់លេខ ៥ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីគ្រប់គ្រង ចំនួន ០៤ រូប នៃសាកលវិទ្យាល័យស្វាយរៀង ដូចមានរាយនាមខាងក្រោម :

១- លោក **ឃួច សុឃុន** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស

២- លោក **ចាប់ ចន្ទណារ៉ា** ជាព្រឹទ្ធបុរសមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

៣- លោក **គួខ សុខចាន់** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៤- លោក **សំ មណ្ណជ័យ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យកសិកម្ម

៥- លោក **សួស យុត្ថារី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។.

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៨៦ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនអ្នកជំនាញបច្ចេកទេស និងប្រធានអង្គការ KOICA ប្រចាំនៅកម្ពុជា ចំនួន០៣រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការនិងជួយកសាងបង្គោលប្រឹថពីវិភាគ នៅព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ :**

-លោក KIM BYUNG KWAN តំណាងអង្គការ KOICA ប្រចាំកម្ពុជា

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា :**

-លោក CHO SUNG TAE ប្រធានក្រុមហ៊ុនសាំប៊ូវិស្វកម្ម

**គ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :**

-លោក KANG MOON SUN

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ប្រគល់ភារកិច្ចជូនលោក **សុខ ចេង** ជាអគ្គនាយករង នៃ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៦៤៧ អនក្រ.តត**

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តបន្ទាយមានជ័យ ចំនួន ០៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយសុវត្ថារា ថ្នាក់ សេនា :**

| | | | |
|---|---|---|---|
| ១- | លោក | **ឃុំ គីលីន** | អនុប្រធានមន្ទីរ ប.ទ |
| ២- | លោក | **ចៅ ទុត** | អនុប្រធានមន្ទីរ ប.ទ |

**ខ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :**

| | | | |
|---|---|---|---|
| ១- | លោក | **ជុំ ចណ្ឌី** | អនុប្រធានមន្ទីរ ប.ទ |
| ២- | លោក | **ហម ម៉ិច** | ប្រធានរដ្ឋបាល មន្ទីរ ប.ទ |

៣- លោកស្រី ឈាច អានិត្យានី ប្រធានការិយាល័យប្រៃសណីយ៍ មន្ទីរ ប.ទ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៦៨៥ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃមន្ទីរ ប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្តបន្ទាយមានជ័យ ចំនួន ១៥រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ :**

| | | | |
|---|---|---|---|
| ១- | លោក | ឈន ស៊ីណា | មន្ត្រីរដ្ឋបាល |
| ២- | លោកស្រី | ផេង ផល្លី | បញ្ជរប្រៃសណីយ៍ |
| ៣- | លោកស្រី | ខែត្រ ស៊ីថនដេត | បុគ្គលិក |
| ៤- | លោក | ឌិត្យ សំផន | ប្រធានការិយាល័យ ប.ទ ក្រុងប៉ោយប៉ែត |
| ៥- | លោក | វ៉ីត សារ៉ែម | ប្រធានការិយាល័យ ប.ទ ក្រុងម៉ាឡៃ |
| ៦- | លោក | ឈុន ម៉ិនហេង | ប្រធានការិយាល័យ ប.ទ ស្រុកព្រះនេត្រព្រះ |
| ៧- | លោក | ចិន វណ្ណវឌ្ឍន៍ | ប្រធានការិយាល័យ ប.ទ ស្រុកមង្គលបុរី |
| ៨- | លោកស្រី | លាច អាទិត្យណា | អនុប្រធានការិយាល័យ ប.ទ ក្រុងប៉ោយប៉ែត |
| ៩- | លោក | ស្រី សារ៉េត | ជំនួយការចែកចាយលិខិត |

ខ-មេជាងប្រាក់ការងារ :

| | | | |
|---|---|---|---|
| ១- | លោកស្រី | ម៉ុន វ៉ាលីយ៉ា | មន្ត្រីវិទ្យុ |
| ២- | លោស្រី | ឈុក អេង | មន្ត្រីរដ្ឋបាលការិយាល័យ ប.ទ ស្រុកភ្នំស្រុក |
| ៣- | លោក | ប្រាក់ សាវ៉ន | បុគ្គលិក |
| ៤- | លោក | ទូន សីហា | បុគ្គលិក |
| ៥- | លោកស្រី | យឿន សុជាតា | មន្ត្រីរដ្ឋបាល |
| ៦- | លោក | គួច ចាន់ធិត្យ | ជាងគំនូរទន្សាយមាស |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៩

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៩០ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១ៈ** តែងតាំងលោក ម៉ា ឧុន្នី ជាប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ នៃក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៦៣៦ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**មាត្រា១ :** ត្រូវបានតែងតាំងលោក **ទួន ចិន្សៅ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានគណនេយ្យ នៃអគ្គនាយកដ្ឋានរតនាគារជាតិ ជាប្រធាននាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និង សរុបស្ថិតិ នៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួសលោក **ស្រី សាមិត** ដែលត្រូវចូលនិវត្តន៍ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១២៦៩...អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៩ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា ១ :** តែងតាំងមន្ត្រីគ្រប់គ្រង ចំនួន ០៥ រូប នៃសាកលវិទ្យាល័យមានជ័យ ដូចមានរាយនាមខាងក្រោម :

១- លោក **យន ទ្រី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យកសិកម្ម និងកែច្នៃម្ហូបអាហារ

២- លោក **ចាន់ ធឿន** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកទេស

៣- លោក **ជីម សារិន្ទ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

៤- លោក **ទេព ចន្ទី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

៥- លោក **សាំង សុផាត** ជាព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងអភិវឌ្ឍន៍សហគមន៍។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។.

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ [illegible] ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**__កន្លែងទទួល__ :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៦៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ កែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ឯក **សុខ តារា** អត្តលេខ ០០៣៨១១ ជា នាយរង សេនាធិការចំរុះ និងជានាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ទោ **ជាំ ជាវ៉ាន់រិទ្ធ** អត្តលេខ ០០០២៩៣ ជានាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល**
លេខ ៖ ៩៩៥ សហវ.ប្រក

លិខិតចូល
ថ្ងៃទី ០៤ ខែ ១១ ឆ្នាំ 2009

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០០៩

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០១៩ សហវ.ប្រក.គរ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតក្រុមសម្របសម្រួលអន្តរស្ថាប័ន នៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ
- យោងតាមសំណូមពរការងារចាំបាច់

**សម្រេច**

**ប្រការ១:**

ប្រកាសអន្តរក្រសួងនេះមានគោលបំណងរៀបចំជាផ្លូវការ នូវយន្តការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំការសម្របសម្រួលការងាររវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ហៅកាត់ថា អគរ) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាស្ថាប័នប្រតិបត្តិ និងក្រសួងសុខាភិបាលដែលជាស្ថាប័នឯកទេស តាមបញ្ញត្តិជំពូក ៣ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដែលត្រូវបញ្ជាក់ពីតួនាទី ការទទួលខុសត្រូវ និងទម្រង់នៃកិច្ចសហការរបស់ស្ថាប័នទាំងពីរដើម្បីជានាប្រសិទ្ធភាពនៃការគ្រប់គ្រងត្រួតពិនិត្យប្រតិបត្តិការនាំចូល នាំចេញទំនិញ នៅតាមមាត់ច្រកព្រំដែននានានៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគម្រូអនុវត្តល្អបំផុតជាអន្តរជាតិ និងមានបទដ្ឋានរដ្ឋបាលច្បាស់លាស់។

**ប្រការ២:**

កំណត់ទីកន្លែងទំនាក់ទំនងព័ត៌មានដូចខាងក្រោម ៖

ក. សម្រាប់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា:

- អង្គភាព: នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
- មន្ត្រី: លោក ប៉ែន សំអាត ឋានៈ ប្រធាននាយកដ្ឋាន

ទូរស័ព្ទលេខ: (៨៥៥) ១២ ៣៣៦ ៩៩៩ និង (៨៥៥) ១២ ៣២៩ ៣២៩ ទូរសារលេខ: (៨៥៥) ២៣ ២១២ ០៦៥ និងសារអេឡិចត្រូនិក: psa@camnet.com.kh។

ខ. សម្រាប់ក្រសួងសុខាភិបាល

- អង្គភាព: នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង នៃក្រសួងសុខាភិបាល

- មន្ត្រី: លោកស្រី **ទា គីមឆាយ** ឋានៈ ប្រធាននាយកដ្ឋាន

ទូរស័ព្ទលេខ: (៨៥៥) ១២ ៨២២ ៨៧២ ទូរសារលេខ: (៨៥៥) ២៣ ៨៨២ ៣៣០ និងសារអេឡិចត្រូនិក: chhay@forum.org.kh ។

**ប្រការ៣:**

កំណត់ភារកិច្ចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ហៅកាត់ថា អគរ) សម្រាប់ការចូលរួមអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ ៖

- អនុវត្តតាមបញ្ញត្តិអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ព្រមទាំងមានការកិច្ចសម្របសម្រួល សហការអនុវត្តតាមសំណើកែតម្រូវ ឬបំពេញបន្ថែមបញ្ជីនេះពីក្រសួងសុខាភិបាល។
- ធ្វើសកម្មភាពត្រួតពិនិត្យ និងវាយតម្លៃលើឯកសារ ឬត្រួតពិនិត្យរូបវន្តលើទំនិញនាំចូល នាំចេញ នៅមាត់ច្រកអន្តរជាតិ តាមការតម្រូវស្របតាមសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ប្រសិនបើមានការតម្រូវ។
- ផ្តល់ឯកសារថតចម្លងពាក់ព័ន្ធនឹងការត្រួតពិនិត្យទំនិញ ដែលស្ថិតក្រោមការគ្រប់គ្រង និងក្នុងនាមក្រសួងសុខាភិបាល ទៅទីកន្លែងដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ។
- ជាស្ថាប័ននាំមុខតែមួយគត់ ដែលទទួលខុសត្រូវលើការត្រួតពិនិត្យទំនិញនៅមាត់ច្រកអន្តរជាតិ ។ ក្នុងករណីតម្រូវឱ្យមានការចូលរួមត្រួតពិនិត្យដោយក្រសួងសុខាភិបាល និង/ឬស្ថាប័នផ្សេងទៀត អគរ ត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យឱ្យធ្វើឡើងរួមគ្នាតែមួយលើកស្របតាមបញ្ញត្តិមាត្រា ៥ ជំពូក ២ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។
- ក្នុងករណីតម្រូវឱ្យមានអ្នកឯកទេសជាក់លាក់ ដែលមិនមាននៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងកាំកុងត្រូល អគរ ត្រូវស្នើសុំទៅក្រសួងសុខាភិបាល នូវអ្នកឯកទេសពាក់ព័ន្ធមកចូលរួមក្នុងដំណើរការត្រួតពិនិត្យ ។/

- អគរ ត្រូវសហការផ្លាស់ប្តូរទិន្នន័យ ឬសូចនាករទំនិញនាំចេញ នាំចូល ឬធុរជនពាក់ព័ន្ធនានាជាមួយក្រសួងសុខាភិបាល តាមទីកន្លែងដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ ។
- អគរ ត្រូវផ្សព្វផ្សាយដល់ក្រសួងសុខាភិបាល នូវបទប្បញ្ញត្តិ និងរាល់ការវិវឌ្ឍន៍ពាក់ព័ន្ធដល់កិច្ចដំណើរការអនុវត្តគោលនយោបាយ នៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ និងត្រូវសម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្នុងការធ្វើអង្កេតការវាយតម្លៃ និងការធ្វើចំណាត់ថ្នាក់ធុរជន ឬទំនិញតាមកម្រិតហានិភ័យ ដោយរក្សាឱ្យបាននូវការសម្ងាត់វិជ្ជាជីវៈ ហើយក្នុងករណីយល់ថាចាំបាច់ត្រូវសហការត្រួតពិនិត្យក្រោយពេលបញ្ចេញទំនិញពីគយរួមគ្នា ។

**ប្រការ៤:**

កំណត់កាតព្វកិច្ចរបស់ក្រសួងសុខាភិបាល សម្រាប់ការចូលរួមអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ ៖

- ក្រសួងសុខាភិបាលត្រូវបញ្ជូនបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ដែលបានធ្វើបច្ចុប្បន្នភាព និងបានការសម្រេចពីរាជរដ្ឋាភិបាលកម្ពុជាប្រសិនបើមានការកែសម្រួលជាយថាហេតុមក អគរ ដើម្បីធ្វើចំណាត់ថ្នាក់ទំនិញតាមប្រព័ន្ធស៊ីសថ្នាក់នៃតារាងពន្ធគយកម្ពុជាជាធរមាន ដើម្បីចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និង/ឬបញ្ចូលទៅក្នុងម៉ូឌុលការគ្រប់គ្រងហានិភ័យនៃស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) ។
- ក្រសួងសុខាភិបាលត្រូវបញ្ជូនព័ត៌មានពីទំនិញ ឬមុខសញ្ញាធុរជនដែលជាប់ហានិភ័យខ្ពស់ដែលជាលទ្ធផលនៃការធ្វើអង្កេតវាយតម្លៃរបស់អង្គភាពគ្រប់គ្រងហានិភ័យ របស់ក្រសួងសុខាភិបាល ឬពីប្រភពព័ត៌មានសម្ងាត់ផ្សេងទៀតដែលទទួលបានជាបន្ទាន់មក អគរ ដើម្បីចាត់វិធានការបានទាន់ពេល ។ ប្រសិនបើក្រសួងសុខាភិបាលយល់ថាចាំបាច់ ត្រូវធ្វើការកំណត់ និងបញ្ជាក់ពីសកម្មភាពដែល អគរ ត្រូវអនុវត្តក្នុងការត្រួតពិនិត្យទំនិញដែលឆ្លងកាត់នៅតាមបណ្តាមាត់ច្រកព្រំដែន ឬតម្រូវការចូលរួមត្រួតពិនិត្យរូបវន្តជាយថាហេតុ លើជើងដឹកជញ្ជូនណាមួយក្រោមការសម្របសម្រួលរបស់ អគរ ។
- តាមសំណើសុំចូលរួមត្រួតពិនិត្យ ឬអន្តរាគមន៍នានាជាលាយលក្ខណ៍អក្សររបស់ អគរ ក្រសួងសុខាភិបាល ត្រូវបញ្ជូនចម្លើយមក អគរ ពីលទ្ធភាពនៃការចូលរួមត្រួតពិនិត្យ ឬការតម្រូវឱ្យ អគរ ធ្វើសកម្មភាពជាក់លាក់ណាមួយផ្សេងជំនួសវិញ ។ ប្រសិនបើក្រសួងសុខាភិបាលខកខានមិនបានឆ្លើយតបក្នុងរយៈពេល ០៨ ម៉ោងនៃម៉ោងធ្វើការ ក្រោយពីក្រសួងសុខាភិបាលបានទទួលសំណើស្នើសុំ អគរ អាចចាត់វិធានការបានដោយខ្លួនឯង ។

**ប្រការ៥:**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ /

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
លេខ : ៩៩៦ សហវ.ប្រក

លិខិតចូល
ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ2009

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០០៩

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឲ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១០១៩ សហវ.ប្រក.គរ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើតក្រុមសម្របសម្រួលអន្តរស្ថាប័ន នៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ
- យោងតាមសំណូមពរការងារចាំបាច់

**សម្រេច**

**ប្រការ១:**

ប្រកាសអន្តរក្រសួងនេះមានគោលបំណងរៀបចំជាផ្លូវការ នូវយន្តការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរៀបចំការសម្របសម្រួលការងាររវាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា (ហៅកាត់ថា អគរ) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាស្ថាប័នប្រតិបត្តិ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលជាស្ថាប័នឯកទេស តាមបញ្ញត្តិជំពូក ៣ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដែលត្រូវបញ្ជាក់ពីតួនាទី ការទទួលខុសត្រូវ និងទម្រង់នៃកិច្ចសហការរបស់ស្ថាប័នទាំងពីរ ដើម្បីជានាប្រសិទ្ធភាពនៃការគ្រប់គ្រងត្រួតពិនិត្យប្រតិបត្តិការនាំចូល នាំចេញទំនិញនៅតាមមាត់ច្រកព្រំដែននានានៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគម្រូអនុវត្តល្អបំផុតជាអន្តរជាតិ និងមានបទដ្ឋានរដ្ឋបាលច្បាស់លាស់។

**ប្រការ២:**

កំណត់ទីកន្លែងទំនាក់ទំនងព័ត៌មានដូចខាងក្រោម ៖

ក. សម្រាប់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា:

- អង្គភាព: នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
- មន្ត្រី: លោក **ប៉ែន សំអាត** ឋាន: ប្រធាននាយកដ្ឋាន

ទូរស័ព្ទលេខ: (៨៥៥) ១២ ៣៣៦ ៩៩៩ និង (៨៥៥) ១២ ៣២៩ ៣២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៤ ០៦៩ និងសារអេឡិចត្រូនិក: psa@camnet.com.kh។

ខ. សម្រាប់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- អង្គភាព: ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- មន្ត្រី: ឯកឧត្តម ម៉េង សក្តិធារ៉ា ឋានៈ អគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្ម ទូរស័ព្ទលេខ: (៨៥៥) ១២ ៩១៩ ០១៣ ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣ និង សារអេឡិចត្រូនិក: mime_pmo@camintel.com ។

**ប្រការ៣:**

កំណត់ភារកិច្ចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ហៅកាត់ថា អគរ) សម្រាប់ការចូលរួមអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ ៖

- អនុវត្តតាមបញ្ញត្តិអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ព្រមទាំងមានការកិច្ចសម្របសម្រួល សហការអនុវត្តតាមសំណើកែតម្រូវ ឬបំពេញបន្ថែមបញ្ជីនេះពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- ធ្វើសកម្មភាពត្រួតពិនិត្យ និងវាយតម្លៃលើឯកសារ ឬត្រួតពិនិត្យរូបវន្តលើទំនិញនាំចូល នាំចេញ នៅមាត់ច្រកអន្តរជាតិ តាមការតម្រូវស្របតាមសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- ផ្តល់ឯកសារថតចម្លងពាក់ព័ន្ធនឹងការត្រួតពិនិត្យទំនិញ ដែលស្ថិតក្រោមការគ្រប់គ្រង និងក្នុងនាមក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទៅទីកន្លែងដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ ។
- ជាស្ថាប័ននាំមុខតែមួយគត់ ដែលទទួលខុសត្រូវលើការត្រួតពិនិត្យទំនិញនៅមាត់ច្រកអន្តរជាតិ ។ ក្នុងករណីតម្រូវអោយមានការចូលរួមត្រួតពិនិត្យដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង/ឬ ស្ថាប័នផ្សេងទៀត អគរ ត្រូវសម្របសម្រួលដល់ការត្រួតពិនិត្យឲ្យធ្វើឡើងរួមគ្នាតែមួយលើក ស្របតាមបញ្ញត្តិមាត្រា ៥ ជំពូក ២ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ។
- ក្នុងករណីតម្រូវអោយមានអ្នកឯកទេសជាក់លាក់ ដែលមិនមាននៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងកាំកុងត្រូល អគរ ត្រូវស្នើសុំទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នូវអ្នកឯកទេសពាក់ព័ន្ធមកចូលរួមក្នុងដំណើរការត្រួតពិនិត្យ ។
- អគរ ត្រូវសហការផ្លាស់ប្តូរទិន្នន័យ ឬសូចនាករទំនិញនាំចេញ នាំចូល ឬធុរជនពាក់ព័ន្ធនានាជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមទីកន្លែងដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ ។/

- អគរ ត្រូវផ្សព្វផ្សាយដល់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នូវបទបញ្ញត្តិ និងរាល់ការវិវឌ្ឍន៍ពាក់ព័ន្ធដល់កិច្ចដំណើរការអនុវត្តគោលនយោបាយ នៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ និងត្រូវសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការធ្វើអង្កេតការវាយតម្លៃ និងការធ្វើចំណាត់ថ្នាក់ធុរជន ឬទំនិញតាមកម្រិតហានិភ័យ ដោយរក្សាឲ្យបាននូវការសម្ងាត់វិជ្ជាជីវៈ ហើយក្នុងករណីយល់ថាចាំបាច់ត្រូវសហការត្រួតពិនិត្យក្រោយពេលបញ្ចេញទំនិញពីគយរួមគ្នា ។

**ប្រការ៤:**

កំណត់កាតព្វកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សម្រាប់ការចូលរួមអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដូចតទៅ ៖

- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបញ្ជូនបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ដែលបានធ្វើបច្ចុប្បន្នភាព និងបានការសម្រេចពីរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើមានការកែសម្រួលជាយថាហេតុមក អគរ ដើម្បីធ្វើចំណាត់ថ្នាក់ទំនិញតាមប្រព័ន្ធស៊ីសង្វាក់នៃតារាងពន្ធគយកម្ពុជាជាធរមាន ដើម្បីចាត់ចែងអនុវត្តឲ្យមានប្រសិទ្ធភាព និង/ឬ បញ្ចូលទៅក្នុងម៉ូឌុលការគ្រប់គ្រងហានិភ័យនៃស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) ។
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបញ្ជូនព័ត៌មានពីទំនិញ ឬមុខសញ្ញាធុរជនដែលជាប់ហានិភ័យខ្ពស់ដែល ជាលទ្ធផលនៃការធ្វើអង្កេតវាយតម្លៃរបស់អង្គភាពគ្រប់គ្រងហានិភ័យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬពីប្រភពព័ត៌មានសម្ងាត់ផ្សេងទៀតដែលទទួលបានជាបន្ទាន់មក អគរ ដើម្បីចាត់វិធានការបានទាន់ពេល ។ ប្រសិនបើក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលយល់ថាចាំបាច់ ត្រូវធ្វើការកំណត់ និងបញ្ជាក់ពីសកម្មភាពដែល អគរ ត្រូវអនុវត្តក្នុងការត្រួតពិនិត្យទំនិញដែលឆ្លងកាត់នៅតាមបណ្ដាមាត់ច្រកព្រំដែន ឬតម្រូវការចូលរួមត្រួតពិនិត្យរូបវន្តជាយថាហេតុ លើជើងដឹកជញ្ជូនណាមួយក្រោមការសម្របសម្រួលរបស់ អគរ ។
- តាមសំណើសុំចូលរួមត្រួតពិនិត្យ ឬអន្តរាគមន៍នានាជាលាយលក្ខណ៍អក្សររបស់ អគរ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបញ្ជូនចម្លើយមក អគរ ពីលទ្ធភាពនៃការចូលរួមត្រួតពិនិត្យ ឬការតម្រូវឲ្យ អគរ ធ្វើសកម្មភាពជាក់លាក់ណាមួយផ្សេងជំនួសវិញ ។ ប្រសិនបើក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលខកខានមិនបានឆ្លើយតបក្នុងរយៈពេល ០៨ ម៉ោងនៃម៉ោងធ្វើការ ក្រោយពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានទទួលសំណើស្នើសុំ អគរ អាចចាត់វិធានការបានដោយខ្លួនឯង ។

**ប្រការ៥:**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ,
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៦៥៧ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០៩

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

